Washington State Health Care Authority

# Notice of Privacy Practices (លិខិតជូនដំណឹងអំពីការអនុវត្តឯកជនភាព)

ចូលជាធរមាននៅខែមករា ឆ្នាំ 2024

*លិខិតជូនដំណឹងនេះពិពណ៌នាអំពីរបៀបដែល Health Care Authority (អាជ្ញាធរថែទាំសុខភាព, HCA, យើង ឬយើងខ្ញុំ) រដ្ឋ Washington ប្រើប្រាស់ ឬបញ្ចេញព័ត៌មានវេជ្ជសាស្ត្រអំពីអ្នក និងរបៀបដែលអ្នកអាចទទួលបានព័ត៌មាននេះ។ សូមពិនិត្យមើលឡើងវិញដោយប្រុងប្រយ័ត្ន។*

## ហេតុអ្វីបានជាខ្ញុំទទួលបានលិខិតជូនដំណឹងនេះ?

HCA ប្តេជ្ញាការពារព័ត៌មានសុខភាពរបស់អ្នក។ ច្បាប់តម្រូវឱ្យយើងផ្តល់លិខិតជូនដំណឹងនេះដល់សមាជិកទាំងអស់ ដូច្នេះអ្នកដឹងពីរបៀបដែលយើងអាចប្រើប្រាស់ ឬបញ្ចេញព័ត៌មានរបស់អ្នក។ លិខិតជូនដំណឹងនេះមិនប៉ះពាល់ដល់សិទ្ធិទទួលបានសេវាកម្ម ឬការធានារ៉ាប់រងរបស់អ្នកទេ។ បើអ្នកមានសំណួរណាមួយអំពីលិខិតជូនដំណឹងនេះ សូមទាក់ទងការិយាល័យឯកជនភាព HCA ដោយផ្ញើអ៊ីមែលទៅ PrivacyOfficer@hca.wa.gov ហៅទូរសព្ទទៅលេខ 1-844-284-2149 ឬសរសេរទៅកាន់មន្ត្រីឯកជនភាព HCA, Health Care Authority (អាជ្ញាធរថែទាំសុខភាព), P.O. Box 42704, Olympia, WA 98504-2704។

## សេចក្តីសង្ខេប

### 1 សិទ្ធិរបស់អ្នក

**អ្នកមានសិទ្ធិ៖**

- ទទួលបានច្បាប់ចម្លងនៃកំណត់ត្រាសុខភាព និងពាក្យបណ្តឹងទាមទារសំណងរបស់អ្នក។
- កែតម្រូវកំណត់ត្រាសុខភាព និងពាក្យបណ្តឹងទាមទារសំណងរបស់អ្នក។
- ស្នើសុំការប្រាស្រ័យទាក់ទងជាសម្ងាត់។
- សុំឲ្យយើងកំណត់ព័ត៌មានដែលយើងចែករំលែក។
- ទទួលបានបញ្ជីឈ្មោះ (ដោយមានករណីលើកលែងមួយចំនួន) របស់អ្នកដែលយើងបានចែករំលែកព័ត៌មានរបស់អ្នកជាមួយ។
- ទទួលបានច្បាប់ចម្លងនៃលិខិតជូនដំណឹងអំពីឯកជនភាពនេះ។
- ជ្រើសរើសនរណាម្នាក់ដើម្បីធ្វើការជួសអ្នក។
- ដាក់ពាក្យបណ្តឹង ប្រសិនបើអ្នកជឿថាឯកជនភាពរបស់អ្នកត្រូវបានរំលោភបំពាន។

➢ ***សូមទៅកាន់ទំព័រទី 2 សម្រាប់ព័ត៌មានបន្ថែម***

### 2 ជម្រើសរបស់អ្នក

**អ្នកអាចប្រាប់យើងនូវជម្រើសរបស់អ្នកអំពីព័ត៌មានសុខភាពមួយចំនួនដែលយើងប្រើប្រាស់ ឬចែករំលែក។ ឧទាហរណ៍ របៀបដែលយើង៖**

- ឆ្លើយសំណួរធានារ៉ាប់រងពីក្រុមគ្រួសារ និងមិត្តភក្តិរបស់អ្នក។
- ផ្តល់ជំនួយសង្គ្រោះគ្រោះមហន្តរាយ។

យើងមិនធ្វើទីផ្សារផ្សព្វផ្សាយសេវាកម្មរបស់យើង ឬលក់ព័ត៌មានរបស់អ្នកទេ។

➢ ***សូមទៅកាន់ទំព័រទី 3 សម្រាប់ព័ត៌មានបន្ថែម***

### 3 ការប្រើប្រាស់ និងការបញ្ចេញព័ត៌មានរបស់យើង

**យើងអាចនឹងប្រើប្រាស់ និងចែករំលែកព័ត៌មានរបស់អ្នកដោយហេតុផលទាំងនេះ៖**

- ជួយគ្រប់គ្រងការព្យាបាលថែទាំសុខភាពដែលអ្នកទទួលបាន។
- ដំណើរការអង្គភាពរបស់យើង។
- បង់ថ្លៃសេវាសុខភាពរបស់អ្នក។
- គ្រប់គ្រងផែនការសុខភាពរបស់អ្នក។
- ជួយដោះស្រាយបញ្ហាសុខភាព និងសុវត្ថិភាពសាធារណៈ។
- ធ្វើការស្រាវជ្រាវ។
- អនុវត្តតាមច្បាប់។
- ឆ្លើយតបទៅនឹងសំណើបរិច្ចាគសរីរាង្គ និងជាលិកា ហើយធ្វើការជាមួយគ្រូពេទ្យកោសល្យវិច័យ ឬនាយករៀបចំពិធីបុណ្យសព។
- ដោះស្រាយសំណងរបស់កម្មករ ការអនុវត្តច្បាប់ និងសំណើផ្សេងៗទៀតរបស់រដ្ឋាភិបាល។
- ឆ្លើយតបទៅនឹងពាក្យបណ្តឹង និងចំណាត់ការផ្លូវច្បាប់។
- កំណត់ឱកាសកែលម្អគុណភាព។

➢ ***សូមទៅកាន់ទំព័រទី 4 សម្រាប់ព័ត៌មានបន្ថែម***

## 4 សិទ្ធិរបស់អ្នក

**នៅពេលនិយាយអំពីព័ត៌មានសុខភាពរបស់អ្នក អ្នកមានសិទ្ធិមួយចំនួន។** ផ្នែកនេះពន្យល់អំពីសិទ្ធិរបស់អ្នក និងទំនួលខុសត្រូវមួយចំនួនរបស់យើងដើម្បីជួយអ្នក។ បើអ្នកចង់អនុវត្តសិទ្ធិរបស់អ្នក ឬមានសំណួរផ្សេងទៀតទាក់ទងនឹងព័ត៌មានសុខភាពរបស់អ្នកដែល HCA ទទួលបាន សូមទាក់ទងការិយាល័យឯកជនភាព HCA ដោយផ្ញើអ៊ីមែលទៅ **PrivacyOfficer@hca.wa.gov** ហៅទូរសព្ទទៅ 1-844-284-2149 ឬសរសេរលិខិតទៅកាន់មន្ត្រីឯកជនភាព HCA, Health Care Authority (អាជ្ញាធរថែទាំសុខភាព), P.O. Box 42704, Olympia, WA 98504-2704។

**អ្នកមានសិទ្ធិ៖**

**ទទួលបានច្បាប់ចម្លងនៃកំណត់ត្រាសុខភាព និងពាក្យបណ្តឹងទាមទារសំណងរបស់អ្នក**
អ្នកអាចពិនិត្យមើលឡើងវិញនូវព័ត៌មានផ្ទាល់ខ្លួនដែល HCA មានអំពីអ្នកដោយសួរ ជាលាយលក្ខណ៍អក្សរដើម្បីមានសិទ្ធិចូលមើល ឬទទួលបានច្បាប់ចម្លងរបស់វា។ យើងអាចនឹងគិតថ្លៃសម្រាប់ច្បាប់ចម្លង។ ក្នុងស្ថានភាពជាច្រើន យើងនឹងផ្តល់ជូនច្បាប់ចម្លងជាទម្រង់អេឡិចត្រូនិកតាមការស្នើសុំ។

លើកលែងតែការលើកលែងដែលមានរាយខាងក្រោម នេះជាកំណត់ត្រាដែលអ្នកអាចពិនិត្យមើលឡើងវិញ និងចម្លង៖

- កំណត់ត្រាអំពីការចុះឈ្មោះ ការបង់ប្រាក់ ការវិនិច្ឆ័យក្តីទាមទារសំណង និងការគ្រប់គ្រងករណី ឬផ្នែកវេជ្ជសាស្ត្រដែលរក្សាដោយ ឬជំនួស HCA។
- កំណត់ត្រាផ្សេងទៀតដែល HCA ប្រើដើម្បីធ្វើការសម្រេចចិត្តអំពីអ្នក។

ព័ត៌មានដែលអ្នកអាចនឹងពិនិត្យឡើងវិញ និងចម្លងមិនរួមបញ្ចូល៖
- កំណត់ចំណាំអំពីការព្យាបាលចិត្តសាស្ត្រ។
- ព័ត៌មានដែលចងក្រងដោយសមហេតុផលក្នុងការរំពឹងទុក ឬសម្រាប់ប្រើប្រាស់ក្នុងបណ្តឹងរដ្ឋប្បវេណី ឧក្រិដ្ឋកម្ម ឬរដ្ឋបាល ឬដំណើរការនីតិវិធី។
- ព័ត៌មានដែល HCA មិនអាចបញ្ចេញដោយស្របច្បាប់ឲ្យអ្នកបាន។
- ព័ត៌មានដែលទទួលបានពីអ្នកផ្សេងក្រៅពីអ្នកផ្តល់សេវាថែទាំសុខភាពក្រោមការសន្យានៃការរក្សាការសម្ងាត់ ប្រសិនបើការស្នើសុំចូលមើលនោះទំនងជានឹងបង្ហាញពីប្រភពនៃព័ត៌មានយ៉ាងសមហេតុសមផល។
- ព័ត៌មានដែលអ្នកជំនាញថែទាំសុខភាពដែលមានអាជ្ញាបណ្ណ ឬ HCA សម្រេចមិនគួរត្រូវបានបញ្ចេញទៅឲ្យអ្នក ពីព្រោះវាអាចបង្កគ្រោះថ្នាក់ដល់អ្នក ឬអ្នកផ្សេងទៀត។

**សុំឱ្យយើងកែកំណត់ត្រាសុខភាព និងពាក្យបណ្តឹងទាមទារសំណង**
- អ្នកអាចនឹងស្នើសុំឱ្យយើងកែប្រែព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ប្រសិនបើអ្នកជឿថាវាមិនត្រឹមត្រូវ ឬមិនពេញលេញ។ អ្នកត្រូវតែធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរ កំណត់ព័ត៌មានណាមួយដែលអ្នកចង់ផ្លាស់ប្តូរ និងពន្យល់ពីមូលហេតុដែលគួរតែផ្លាស់ប្តូរវា។
- HCA មិនចាំបាច់តម្រូវឱ្យធ្វើការផ្លាស់ប្តូរដែលអ្នកស្នើសុំនោះទេ។ ឧទាហរណ៍ HCA មិនត្រូវបានតម្រូវឱ្យផ្លាស់ប្តូរព័ត៌មានដែលខ្លួនមិនបានបង្កើត ឬព័ត៌មានដែលត្រឹមត្រូវឡើយ។ បើ HCA មិនធ្វើការផ្លាស់ប្តូរតាមដែលអ្នកស្នើសុំទេ ខ្លួននឹងប្រាប់អ្នកពីមូលហេតុ។ បើ HCA ធ្វើការផ្លាស់ប្តូរ ខ្លួននឹងខិតខំប្រឹងប្រែងធ្វើយ៉ាងណាជូនដំណឹងដល់អ្នកផ្សេងទៀតដែលខ្លួនបានផ្តល់ព័ត៌មាន ឬអ្នកផ្សេងទៀតដែលអ្នកប្រាប់ HCA ថាបានទទួលព័ត៌មាន។

**ស្នើសុំការប្រាស្រ័យទាក់ទងជាសម្ងាត់**
- អ្នកអាចស្នើសុំឱ្យយើងទាក់ទងអ្នកតាមមធ្យោបាយជាក់លាក់មួយ (ឧទាហរណ៍ ទូរសព្ទផ្ទះ ឬទូរសព្ទការិយាល័យ) ឬផ្ញើសំបុត្រទៅអាសយដ្ឋានផ្សេង។
- យើងនឹងពិចារណារាល់សំណើដែលសមហេតុផល ហើយត្រូវតែនិយាយថា “បាទ/ចាស” ប្រសិនបើអ្នកប្រាប់យើងថា អ្នកនឹងមានគ្រោះថ្នាក់ ប្រសិនបើយើងមិនធ្វើ។

**ស្នើសុំការរឹតបន្តឹង (ការបញ្ចេញមានកំណត់)**
- អ្នកអាចស្នើសុំឱ្យយើងកុំប្រើ ឬចែករំលែកព័ត៌មានសុខភាពជាក់លាក់សម្រាប់ការព្យាបាល ការបង់ប្រាក់ ឬប្រតិបត្តិការរបស់យើងបាន។
- យើងមិនត្រូវបានតម្រូវឱ្យយល់ព្រមតាមសំណើរបស់អ្នកទេ ហើយយើងអាចនឹងនិយាយថា "ទេ" ប្រសិនបើវានឹងប៉ះពាល់ដល់ការថែទាំរបស់អ្នក។

**ទទួលបានបញ្ជីឈ្មោះរបស់អ្នកដែលយើងបានចែករំលែកព័ត៌មានជាមួយ**
អ្នកអាចស្នើសុំបញ្ជីឈ្មោះអង្គភាពដែល HCA បានបញ្ចេញព័ត៌មានរបស់អ្នកទៅឲ្យ។ បញ្ជីឈ្មោះនេះនឹងមិនរួមបញ្ចូលការបញ្ចេញទាំងអស់ទេ។ ឧទាហរណ៍ បញ្ជីនេះនឹងមិនរួមបញ្ចូល៖

- ការបញ្ចេញព័ត៌មានសម្រាប់ការព្យាបាល ការបង់ប្រាក់ និងប្រតិបត្តិការថែទាំសុខភាព។
- ការបញ្ចេញព័ត៌មានជូនអ្នក ឬដោយមានការអនុញ្ញាតពីអ្នក។
- ការបញ្ចេញព័ត៌មានបានធ្វើឡើងច្រើនជាងប្រាំមួយឆ្នាំមុនការស្នើសុំរបស់អ្នក។

HCA នឹងឆ្លើយតបទៅអ្នកក្នុងរយៈពេល 60 ថ្ងៃបន្ទាប់ពីថ្ងៃស្នើសុំរបស់អ្នក។ បើអ្នកស្នើសុំគណនេយ្យច្រើនជាងមួយក្នុងរយៈពេល 12 ខែណាមួយ HCA អាចនឹងគិតថ្លៃសេវាសមរម្យ។

**ទទួលបានច្បាប់ចម្លងនៃលិខិតជូនដំណឹងអំពីឯកជនភាពនេះ**

- អ្នកអាចស្នើសុំច្បាប់ចម្លងក្រដាសនៃលិខិតជូនដំណឹងនេះនៅពេលណាក៏បាន ទោះបីជាអ្នកបានយល់ព្រមទទួលលិខិតជូនដំណឹងតាមអេឡិចត្រូនិកក៏ដោយ។ យើងនឹងផ្តល់ឱ្យអ្នកនូវច្បាប់ចម្លងក្រដាសមួយច្បាប់ភ្លាម។

**ជ្រើសរើសនរណាម្នាក់ដើម្បីធ្វើការជួសអ្នក**

- បើអ្នកបានផ្តល់ឱ្យនរណាម្នាក់នូវលិខិតផ្ទេរសិទ្ធិផ្នែកវេជ្ជសាស្ត្រ ឬប្រសិនបើនរណាម្នាក់ជាអាណាព្យាបាលស្របច្បាប់របស់អ្នក បុគ្គលនោះអាចប្រើប្រាស់សិទ្ធិរបស់អ្នក និងធ្វើការជ្រើសរើសអំពីព័ត៌មានសុខភាពរបស់អ្នកបាន។
- យើងនឹងធ្វើឱ្យប្រាកដថាបុគ្គលនោះមានសិទ្ធិអំណាចនេះ ហើយអាចធ្វើការជួសអ្នក មុនពេលយើងចាត់វិធានការណាមួយ។

**ដាក់ពាក្យបណ្តឹង ប្រសិនបើអ្នកមានអារម្មណ៍ថាសិទ្ធិរបស់អ្នកត្រូវបានរំលោភបំពាន**
ប្រសិនបើអ្នកជឿថាឯកជនភាពរបស់អ្នកត្រូវបានរំលោភបំពាន ឬអ្នកមានសំណួរ៖

- សូមទាក់ទងការិយាល័យឯកជនភាព HCA ដោយផ្ញើអ៊ីមែលទៅ **PrivacyOfficer@hca.wa.gov** ដោយហៅទូរសព្ទទៅលេខ 1-844-284-2149 ឬសរសេរលិខិតទៅកាន់មន្ត្រីឯកជនភាព HCA, Health Care Authority (អាជ្ញាធរថែទាំសុខភាព), P.O. Box 42704, Olympia, WA 98504-2704 ឬ
- អ្នកអាចដាក់ពាក្យបណ្តឹងទៅកាន់ការិយាល័យសិទ្ធិស៊ីវិលនៅ Department of Health and Human Services (ក្រសួងសេវាសុខាភិបាល និងសេវាមនុស្ស) សហរដ្ឋអាមេរិកដោយផ្ញើលិខិតទៅកាន់ 200 Independence Avenue, S.W., Washington, D.C. 20201 ដោយទូរសព្ទទៅលេខ 1-877-696-6775 ឬចូលទៅកាន់គេហទំព័រ **www.hhs.gov/ocr/privacy/hipaa/complaints/**។
- យើងនឹងមិនសងសឹកអ្នកចំពោះការដាក់ពាក្យបណ្តឹងនោះទេ។

## 5 ជម្រើសរបស់អ្នក

**សម្រាប់ព័ត៌មានសុខភាពជាក់លាក់ អ្នកអាចប្រាប់យើងនូវជម្រើសរបស់អ្នកអំពីអ្វីដែលយើងចែករំលែក។** ប្រសិនបើអ្នកមានការចង់បានច្បាស់លាស់អំពីរបៀបដែលយើងចែករំលែកព័ត៌មានរបស់អ្នកក្នុងស្ថានភាពដែលបានពិពណ៌នាខាងក្រោម សូមនិយាយជាមួយពួកយើង។ សូមប្រាប់យើងនូវអ្វីដែលអ្នកចង់ឱ្យយើងធ្វើ ហើយយើងនឹងធ្វើតាមការណែនាំរបស់អ្នក។

**ក្នុងករណីទាំងនេះ អ្នកមានទាំងសិទ្ធិ និងជម្រើសក្នុងការប្រាប់យើងឱ្យ៖**

- ចែករំលែកព័ត៌មានជាមួយក្រុមគ្រួសារ មិត្តជិតស្និទ្ធ ឬអ្នកផ្សេងទៀតដែលពាក់ព័ន្ធនឹងការបង់ប្រាក់សម្រាប់ការថែទាំរបស់អ្នក។
- ចែករំលែកព័ត៌មានក្នុងស្ថានភាពសង្គ្រោះគ្រោះមហន្តរាយ។

*បើអ្នកមិនអាចប្រាប់យើងពីការចង់បានរបស់អ្នក ឧទាហរណ៍ បើអ្នកសន្លប់ យើងអាចបន្តចែករំលែកព័ត៌មានរបស់អ្នក បើយើងជឿថាវាជាឧត្តមប្រយោជន៍របស់អ្នក។ យើងក៏អាចចែករំលែកព័ត៌មានរបស់អ្នកនៅពេលចាំបាច់ផងដែរ ដើម្បីកាត់បន្ថយការគំរាមកំហែងធ្ងន់ធ្ងរ និងភ្លាមៗចំពោះសុខភាព ឬសុវត្ថិភាព។*

## ការប្រើប្រាស់ និងការបញ្ចេញព័ត៌មានរបស់យើង

**តើជាធម្មតាយើងប្រើប្រាស់ ឬចែករំលែកព័ត៌មានសុខភាពរបស់អ្នកដោយរបៀបណា?** ជាធម្មតា យើងប្រើប្រាស់ ឬចែករំលែកព័ត៌មានសុខភាពរបស់អ្នកតាមវិធីខាងក្រោម។

**ជួយគ្រប់គ្រងការព្យាបាលថែទាំសុខភាពដែលអ្នកទទួលបាន**

នេះរួមមានការថែទាំដែលបានផ្តល់ជូនអ្នក និងការសម្របសម្រួល ឬការគ្រប់គ្រងការថែទាំរបស់អ្នក។ ឧទាហរណ៍ HCA អាចនឹងបញ្ចេញព័ត៌មានដើម្បីជូនដំណឹងដល់អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកចំពោះបញ្ហាដែលអាចកើតមាននៅក្នុងការថែទាំរបស់អ្នក។

**ដំណើរការអង្គភាពរបស់យើង**

- យើងអាចប្រើប្រាស់ និងបញ្ចេញព័ត៌មានរបស់អ្នក ដើម្បីដំណើរការអង្គភាពរបស់យើង ហើយទាក់ទងអ្នកនៅពេលចាំបាច់។
- យើងមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ព័ត៌មានសេនេទិចដើម្បីសម្រេចថាតើយើងនឹងផ្តល់ឱ្យអ្នកនូវការធានារ៉ាប់រង និងតម្លៃនៃការធានារ៉ាប់រងនោះទេ។ នេះមិនអនុវត្តចំពោះផែនការ long term care (ថៃទាំរយៈពេលវែង) ទេ។

***ឧទាហរណ៍៖ យើងប្រើប្រាស់ព័ត៌មានសុខភាពអំពីអ្នក ដើម្បីអភិវឌ្ឍសេវាកម្មកាន់តែប្រសើរសម្រាប់អ្នក។***

**បង់ថ្លៃសេវាសុខភាពរបស់អ្នក**

- យើងអាចប្រើប្រាស់ និងបញ្ចេញព័ត៌មានសុខភាពរបស់អ្នក នៅពេលយើងបង់ថ្លៃសេវាសុខភាពដែលមានការរ៉ាប់រងរបស់អ្នក។

***ឧទាហរណ៍៖ យើងអាចនឹងចែករំលែកព័ត៌មានអំពីអ្នកជាមួយវេជ្ជបណ្ឌិតរបស់អ្នក ដើម្បីសម្របសម្រួលការបង់ប្រាក់សម្រាប់ការវះកាត់របស់អ្នក។***

- ប្រសិនបើអ្នកស្នើសុំសវនាការរដ្ឋបាលដើម្បីពិនិត្យឡើងវិញនូវការបដិសេធ ជាធម្មតាយើងត្រូវបញ្ចេញព័ត៌មាននៅក្នុងដំណើរការសវនាការ។

**តើយើងអាចប្រើប្រាស់ ឬចែករំលែកព័ត៌មានសុខភាពរបស់អ្នកដោយរបៀបណាទៀត?** យើងត្រូវបានអនុញ្ញាត ឬតម្រូវឱ្យចែករំលែកព័ត៌មានរបស់អ្នកតាមមធ្យោបាយផ្សេងទៀត – ជាធម្មតានៅក្នុងវិធីដែលរួមចំណែកដល់ផលប្រយោជន៍សាធារណៈ ដូចជាសុខភាពសាធារណៈ និងការស្រាវជ្រាវជាដើម។ យើងត្រូវបំពេញលក្ខខណ្ឌជាច្រើននៅក្នុងច្បាប់ មុនពេលយើងអាចចែករំលែកព័ត៌មានរបស់អ្នកសម្រាប់គោលបំណងទាំងនេះ។ សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រ៖ **hhs.gov/hipaa/for-individuals/guidance-materials-for-consumers/index.html**

**ជួយដោះស្រាយបញ្ហាសុខភាព និងសុវត្ថិភាពសាធារណៈ**

- យើងអាចចែករំលែកព័ត៌មានសុខភាពអំពីអ្នកសម្រាប់ស្ថានភាពមួយចំនួនដូចជា៖
- ការបង្ការជំងឺ។
- ការជួយប្រមូលយកវិញនូវផលិតផល។
- ការរាយការណ៍ពីប្រតិកម្មមិនល្អចំពោះថ្នាំ។
- ការរាយការណ៍ពីការរំលោភបំពាន ការធ្វេសប្រហែស ឬអំពើហិង្សាក្នុងគ្រួសារ។
- ការបង្ការ ឬការកាត់បន្ថយការគំរាមកំហែងធ្ងន់ធ្ងរដល់សុខភាព ឬសុវត្ថិភាពរបស់នរណាម្នាក់។

**ធ្វើការស្រាវជ្រាវ**

- យើងអាចប្រើប្រាស់ ឬចែករំលែកព័ត៌មានរបស់អ្នកសម្រាប់ការស្រាវជ្រាវសុខភាព។

**អនុវត្តតាមច្បាប់**

- យើងនឹងចែករំលែកព័ត៌មានអំពីអ្នក ប្រសិនបើច្បាប់រដ្ឋ ឬសហព័ន្ធទាមទារវា រួមទាំងជាមួយ Department of Health and Human Services (ក្រសួងសេវាសុខាភិបាល និងសេវាមនុស្ស) ប្រសិនបើក្រសួងចង់ឃើញថាយើងកំពុងអនុវត្តតាមច្បាប់ឯកជនភាពរបស់សហព័ន្ធដែរឬអត់នោះ។

**ឆ្លើយតបទៅនឹងសំណើបរិច្ចាគសរីរាង្គ និងជាលិកា ហើយធ្វើការជាមួយគ្រូពេទ្យកោសល្យវិច័យ ឬនាយករៀបចំពិធីបុណ្យសព**

- យើងអាចចែករំលែកព័ត៌មានសុខភាពអំពីអ្នកជាមួយអង្គការលទ្ធកម្មសរីរាង្គ។
- យើងអាចចែករំលែកព័ត៌មានសុខភាពជាមួយអ្នកធ្វើសពវិភាគ គ្រូពេទ្យកោសល្យវិច័យ ឬនាយកពិធីបុណ្យសព នៅពេលបុគ្គលម្នាក់ស្លាប់។

**ដោះស្រាយសំណងរបស់កម្មករ ការអនុវត្តច្បាប់ និងសំណើផ្សេងៗទៀតរបស់រដ្ឋាភិបាល**

- យើងអាចប្រើប្រាស់ ឬចែករំលែកព័ត៌មានសុខភាពអំពីអ្នក៖
    - សម្រាប់ការទាមទារសំណងរបស់កម្មករ។
    - សម្រាប់គោលបំណងអនុវត្តច្បាប់ ឬជាមួយមន្ត្រីអនុវត្តច្បាប់។
    - ជាមួយទីភ្នាក់ងារត្រួតពិនិត្យសុខភាពសម្រាប់សកម្មភាពដែលត្រូវបានអនុញ្ញាតដោយច្បាប់។
    - សម្រាប់មុខងារពិសេសរបស់រដ្ឋាភិបាលដូចជាយោធា សន្តិសុខជាតិ និងសេវាការពារប្រធានាធិបតី។

**ឆ្លើយតបទៅនឹងពាក្យបណ្តឹង និងចំណាត់ការផ្លូវច្បាប់**

- យើងអាចចែករំលែកព័ត៌មានសុខភាពអំពីអ្នកជាការឆ្លើយតបទៅនឹងតុលាការ ឬដីការដ្ឋបាល ឬជាការឆ្លើយតបនឹងដីកាកោះ។

**តើមានប្រភេទព័ត៌មានដែលមានការការពារពិសេសដែរទេ?**
មាន ប្រភេទព័ត៌មានមួយចំនួនមានការការពាររឹងមាំជាងនៅក្រោមច្បាប់របស់រដ្ឋ Washington ឬច្បាប់សហព័ន្ធ។ ការអនុវត្តការបញ្ចេញព័ត៌មានខាងលើមិនចាំបាច់អនុវត្តចំពោះប្រភេទព័ត៌មានដែលមានការការពារពិសេសនោះទេ ដែលរួមមាន៖

- ព័ត៌មានសម្ងាត់ទាក់ទងនឹងមេរោគអេដស៍ ដែលត្រូវបានការពារដោយច្បាប់របស់រដ្ឋ Washington។
- ព័ត៌មានអំពីការព្យាបាលផ្តាច់ញៀនគ្រឿងស្រវឹង និងសារធាតុញៀនដែលត្រូវបានការពារនៅក្រោមច្បាប់របស់រដ្ឋ Washington និងច្បាប់សហព័ន្ធ។
- ព័ត៌មានអំពីការព្យាបាលសុខភាពផ្លូវចិត្តត្រូវបានការពារនៅក្រោមច្បាប់របស់រដ្ឋ Washington និងច្បាប់សហព័ន្ធ។

## 7 ទំនួលខុសត្រូវរបស់យើង

- យើងត្រូវបានតម្រូវដោយច្បាប់ដើម្បីរក្សាភាពឯកជន និងសុវត្ថិភាពនៃ protected health information (ព័ត៌មានសុខភាពដែលត្រូវបានការពារ) របស់អ្នក។
- យើងនឹងប្រាប់អ្នកឱ្យដឹងភ្លាមៗប្រសិនបើមានការរំលោភបំពានដែលអាចធ្វើឱ្យប៉ះពាល់ដល់ឯកជនភាព ឬសុវត្ថិភាពនៃព័ត៌មានរបស់អ្នក។
- យើងត្រូវតែអនុវត្តតាមកាតព្វកិច្ច និងការអនុវត្តឯកជនភាពដែលបានពិពណ៌នានៅក្នុងលិខិតជូនដំណឹងនេះ ហើយផ្តល់ឱ្យអ្នកនូវច្បាប់ចម្លង ប្រសិនបើអ្នកសុំ។
- យើងនឹងមិនប្រើប្រាស់ ឬចែករំលែកព័ត៌មានរបស់អ្នកក្រៅពីអ្វីដែលបានពិពណ៌នានៅទីនេះទេ លុះត្រាតែអ្នកប្រាប់យើងថាយើងអាចសរសេរជាលាយលក្ខណ៍អក្សរបាន។ ប្រសិនបើអ្នកប្រាប់យើងថាយើងអាចធ្វើបាន អ្នកអាចនឹងផ្លាស់ប្តូរចិត្តបានគ្រប់ពេល។ អនុញ្ញាតឱ្យយើងដឹងជាលាយលក្ខណ៍អក្សរ ប្រសិនបើអ្នកប្តូរចិត្ត។

សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័ររបស់រដ្ឋាភិបាលសហព័ន្ធនេះ៖ **hhs.gov/hipaa/for-individuals/notice-privacy-practices/index.html**។

**ការផ្លាស់ប្តូរលក្ខខណ្ឌនៃការជូនដំណឹងនេះ**
យើងអាចផ្លាស់ប្តូរលក្ខខណ្ឌនៃការជូនដំណឹងនេះ ហើយការផ្លាស់ប្តូរនឹងអនុវត្តចំពោះព័ត៌មានទាំងអស់ដែលយើងមានអំពីអ្នក។ យើងនឹងផ្តល់ឱ្យអ្នកនូវសេចក្តីជូនដំណឹងថ្មី ឬប្រាប់អ្នកអំពីវា និងរបៀបទទួលបានច្បាប់ចម្លង។ សេចក្តីជូនដំណឹងដែលបានកែសម្រួលនឹងមាននៅលើគេហទំព័ររបស់យើង ហើយយើងនឹងផ្ញើអ៊ីមែល ឬផ្ញើច្បាប់ចម្លងជូនអ្នកតាមសំណើ។ សេចក្តីជូនដំណឹងនេះមានច្រើនភាសា សូមឆែកគេហទំព័ររបស់យើងនៅ
**www.hca.wa.gov/pages/privacy.aspx**។